**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៧៤១៣ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកណ្តាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌខាងក្រៅពណ៌មាស ខាងក្នុងព័ទ្ធដោយផ្កាវល្លិពណ៌មាស និងខ្សែវណ្ឌខាងក្នុងពណ៌មាស បង្ហាញអំពីផាសុកភាព បរិស្ថានស្អាត និងការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក

- ព្រះករុណាព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរាធិបតី(ព្រះអង្គឌួង)ទ្រង់គង់លើខ្នងសេះលើទម្រនៅក្នុងបុស្បុកពណ៌លឿង ជាតំណាងនៃព្រះមហាក្សត្រ ឬព្រះរាជានៅសម័យឧដុង្គដែលមានភាពអង់អាចក្លាហាន ទប់ស្កាត់ ការពារទឹកដី និងប្រជារាស្ត្រពីការឈ្លានពានរបស់ប្រទេសជិតខាង។ ព្រះបាទអង្គឌួងទ្រង់បានកសាងប្រទេសឡើងវិញដោយបង្កើតនិងកែទម្រង់ស្ថាប័នតុលាការ ស្ថាប័នអប់រំ និងស្ថាប័នជាតិនានា ហើយក៏ជាព្រះរាជនិពន្ធច្បាប់សម្រាប់អប់រំទូន្មាន និងរឿងអប់រំផ្សេងៗទៀត
- ភ្នំព្រះរាជទ្រព្យគ្របដណ្តប់ដោយរុក្ខជាតិពណ៌បៃតង ជាតំណាងនៃភ្នំកើតពីធម្មជាតិ និងជាទីតាំងរាជធានីឧដុង្គមានជ័យ។ ភ្នំព្រះរាជទ្រព្យនេះមានព្រះសក្យមុនីចេតិយសម្រាប់តម្កល់ព្រះអដ្ឋិធាតុជាទីសក្ការបូជារបស់ព្រះសម្មាសម្ពុទ្ធសមណគោតម និងព្រះអដ្ឋិធាតុនៃអតីតព្រះមហាក្សត្រខ្មែរ ហើយក៏ជារមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ ប្រវត្តិសាស្ត្រ និងជាកន្លែងគោរពបូជាបែបព្រះពុទ្ធសាសនាក្នុងពិធីបុណ្យជាតិផ្សេងៗ
- វាលពណ៌បៃតងខ្ចី បង្ហាញអំពីដីបរិបូរដោយជីជាតិសម្រាប់ដាំដំណាំហូបផ្លែ និងបន្លែបង្ការ ព្រមទាំងគ្របដណ្តប់ដោយបរិស្ថានស្អាតនៅក្នុងស្រុក
- ស្លឹកក្រប្រាំពីរកាំពណ៌លឿងទ្រដោយផ្កាក្បាច់ភ្ញីទេសពណ៌មាស បង្ហាញអំពីខ្សែចង្វាក់ផលិតកម្មនៃកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងវប្បធម៌ នៅក្នុងស្រុក
- អក្សរឈ្មោះ«រដ្ឋបាលស្រុកពញាឮ»មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល ត្រូវប្រើប្រាស់ដូចខាងក្រោម៖
- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកពញាឮ
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកពញាឮ
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តកណ្តាល អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ប្រធានក្រុមប្រឹក្សាស្រុកពញាឮ និងអភិបាលនៃគណៈអភិបាលស្រុកពញាឮ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ ១៣កើត...... ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៦...ខែ...ធ្នូ.......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកណ្តាល
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...៧៨១៣...ប្រក ចុះថ្ងៃ...ចន្ទ ១៣រោច........ខែ..មិគសិរ..... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី...១៦..ខែ...ធ្នូ.....ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល។

## និមិត្តសញ្ញារដ្ឋបាលស្រុកពញាឮ